# ១០~ រឿង ត្អែក ១ ជាត្អែក ១០

កាលពីព្រេងនាយ មានបុរសពីនាក់ ម្នាក់ឈ្មោះ អាខិល ម្នាក់ឈ្មោះអាខូច នៅស្រុកទីទៃពីគ្នា គំនិតដោយខ្លួន ។ អាខូចជុះអាចម៍ដាក់ពេញពាង១ ហើយយកអាចម៍ល័ក្ខបិទភ្ជិត យ៉ាងល្អមិនឲ្យក្លិនចេញក្រៅបាន ។ អាខិលធ្វើកាំបិត១ផ្លែប៉ុនចង្កឹះអកកំបោរដងប៉ុនកដៃ ស្រោមធំវែងមួយលូក ។ អាខិលស្ពាយកាំបិតនោះដើរទៅលក់ អាខូចក៏ពុនពាងអាចម៍នោះដើរ ទៅលក់ដែរ ។ អាខិលទៅពីនេះ អាខូចមកពីនោះ ជួបគ្នាកណ្ដាលផ្លូវ អាខូចពពាយនាយថា“ អ្នកអើយទិញផ្អករបស់ខ្ញុំយកទៅពិសា ផ្អកចាវយ៉ាងល្អ ស្ងោរក៏បានចំហុយក៏បានឆ្ងាញ់ណាស់” ។ អាខិលឆ្លើយថា“ ទាល់តែលក់ដាវមិនដាច់ គ្មានលុយទិញ បើខ្ញុំដូរជាដាវនេះ ព្រមដូរឬទេ ?” ។ អាខូចឃើញដាវនេះវែង ក៏ឆ្លើយថា“ ដូរក៏ដូរ” ។ អាខិលប្រគល់ដាវឲ្យអាខូចហើយអួតថា“ដាវខ្ញុំនេះមុតបំផុត មេដែករបស់ខ្ញុំផង បើត្រូវការម្ដងចាំហូតកាប់ អ្នកឯងកុំប្រញាប់ហូតមើលបើហូតលព្រើលៗ ស៊កទៅវិញមិនចុះទេ ដាវខ្ញុំពូកែ ខ្ញុំស្ពាយរបស់ខ្ញុំ បើកុំតែខែនេះក្រម្ហូបណាស់កុំអីខ្ញុំមិនដូរទេ” ។ អាខូចក៏ប្រគល់ពាងអាចម៍ឲ្យទៅអាខិល ហើយហាមថា“ផ្អកខ្ញុំនឹងក៏ដែរ ដល់ពេលស៊ីចាំបើកយកមកចំហុយកុំអាលបើកមើលក្រែង វាស្អុយរុយបែង ក្រែងវាធុំក្អួសស៊ីមិនទាន់អស់វាទៅជាខានឆ្ងាញ់ នឹកឃើញជីដូនជីតា បានតែខ្ញុំស៊ីនៅ” ។ អាទាំងពីរបែកគ្នាទៅដល់ផ្ទះ រាល់ខ្លួនហើយតៀនប្រពន្ធថា“ដណ្ដាំបាយទៅ អញបានផ្អក” ប្រពន្ធថា“បានផ្អកពីណា ?” ។ អាខិលថា“ ដូរដាវគេៗថាផ្អកចាវឆ្ងាញ់ពិសាណាស់” ។ ប្រពន្ធក៏ពេញចិត្តនឹកថា“ បើប្ដីចេះធ្វើកាំបិតដូរផ្អក” ស្ទុះភ្លែតទៅលាងចានដួសបាយ ហើយកាន់កាំបិតយ៉ាងកវិលក៏គិលទៅជិតពាងផ្អកយកកាំបិតគាស់អាចម៍ល័ក្ខនោះរបើកឡើង ហើយលូកបានមួយក្ដាប់ ដាក់ផ្លាប់ទៅក្នុងចានសល់នៅដៃប៉ុន្មានក៏លិទ្ធផ្លប់ភ្លក់មើល ងើបមុខឡើងលើថា“យើ ផ្អកចាវអ្វីក៏ស្អុយដូចអាចម៍ គ្មានឆ្អឹងគ្មានសាច់ កខ្ចិចកខ្ចក់ហ្មត់ផង់យ៉ាងហ្នឹង ធ្វើផ្អកត្រីអ្វី ?” ។ ប្ដីថា“ក្រែង

ត្រីពោ" ។ ប្រពន្ធក៏លូកកូរវាវរកក្បាល លូកបានពាក់កណ្ដាលក្អួតចង្អោរជាង២០វក ។ ដឹងជាក់ជាអាចម៍មិនមែនផ្អក បកបន្ទោសទៅម្ចាស់ដើម ឆ្អើមលេបបាយមិនរួច ។

និយាយពីអាខ្វាចត្រេកអរណាស់ ដើរទៅផ្ទះអួតប្រាប់ប្រពន្ធថា "អាចម៍១ពាងជូរបានដាវមួយដែរ" ទទួលខឹងនឹងឆ្កែវាច្រាសស្លឹកគ្រៃ កន្ត្រាក់ដាវលោតទៅដល់ដី បំរុងនឹងកាប់ឆ្កែសំលាប់ ក៏ចាប់ដកដាវហូតខ្ទាច់ឃើញផ្លែដាវនេះខ្លីកំប៉ិច គេចឡើងទៅលើផ្ទះ បង្ហាញប្រពន្ធមើលសើចទាំងពីរនាក់ សើចហើយប្រាប់ប្រពន្ធថា "ប្រាជ្ញាអានេះស្មើនឹងអញៗ ទៅបបួលវាធ្វើសំឡាញ់ គ្រាន់រកស៊ីពីរនាក់នឹងបានមាសប្រាក់ដោយងាយ" ។ លុះទៅប្រទះនឹងអាខិល ដើរពីនាយសើចព្រាយនិយាយសួរថា "ឯងទៅណា ?" ។ អាខិលឆ្លើយថា "អញមកសុំឯងធ្វើសំឡាញ់" ។ អាមួយក៏ថា "អញមកសុំឯងធ្វើគ្លើដែរ" ហើយក៏សុខចិត្តដើរពីរនាក់ទៅដល់ផ្ទះមហាសេដ្ឋីម្នាក់ចាស់ជរាឈឺស្លាប់ គេដាក់ក្នុងក្ដារមឈូសបំរុងបូជាថ្ងៃស្អែក ចំណែកកូនចៅនិងប្រពន្ធយំសោកគ្រប់គ្នា វេលានោះអាទាំងពីរស៊ើបសួរអ្នកដើរខាងក្រៅថា "អ្នកណាស្លាប់បានជាគេយំ ?" ។ គេប្រាប់ថា "មហាសេដ្ឋីស្លាប់" ។ អាទាំងពីរនាក់គិតគ្នាថា " ឯងត្រូវក្លែងសំបុត្រមួយច្បាប់ទៅប្រាប់គេថា សំបុត្រសេដ្ឋីឱ្យមកយកទ្រព្យរបស់ អញបន្លំលបចូលដេកក្នុងមឈូសពីលើខ្មោចសេដ្ឋីស្ដីតនឹងឯង" ។ អាមួយក៏ទៅបន្លំដេកដូចគំនិត ។ អ្នកនៅជិតមិនបានឃើញមិនបានដឹងដ្បិតភ្នែកខំសម្លឹងប្រឹងឈ្ងោកមើលក្រាំង សូត្រព្រះធម៌ កូនចៅ តូចធំរវល់តែយំសោក ។ អាខ្វាចដើររកក្រដាស់បានធ្វើសំបុត្រក្លែង កាន់ដើរទៅសំដែងសូត្រឱ្យគេស្ដាប់ថា សំបុត្រអំពីមហាសេដ្ឋីប្រាប់មកថា " ចៅខ្វាចកំសត់តាំងពីតូចជាកូនធម៌ឥឡូវអាពុកជរាហើយ កូនអើយ!ចូរទៅយករបស់ទ្រព្យទុកចាយឱ្យសប្បាយចិត្តចុះ" ។ កូនចៅស្រីប្រុសគេមិនសុខចិត្ត ព្រោះត្បិតគ្មានត្រា គ្មានហត្ថលេខាសេដ្ឋី ។ អាខ្វាចឆ្លើយថា " ខ្ញុំសូមសន្យានឹងអស់កូនចៅ អញ្ជើញទៅហៅ ទៅសួរលោកចុះ បើលោកស្ដីនោះខ្ញុំត្រង់ពិត បើលោកស្ងៀមនោះខ្ញុំក្លែងបញ្ឆោតទេ" ។ កូនសេដ្ឋីកូនភ្លាមទៅស្រែកហៅឪពុក ។ អាខិលឆ្លើយថា " អើ! " ។

កូនសួរថា " ឪពុកបានឱ្យសំបុត្រទៅកូនធម៌មកយករបស់មែន ឬ ?" ។ អាខិលឆ្លើយថា "អើ! កូនអញឈ្មោះអាខ្វាចវាមកហើយឬ ?" ។ កូនឆ្លើយថា "ទានប្រុស! មកហើយ" ។ អាខិលថា " អើ! មើលយករទេះមួយធំ ក្របីមួយនឹមទឹមរទេះនោះហើយយកមាសប្រាក់កែវកងសំពត់អាវ វាល់ផ្ទុកក្នុងរទេះឱ្យល្មមតែក្របីនោះអូសរួចបានប៉ុន្មានឱ្យវាយកទៅចុះ" ។ កូនចៅស្រីប្រុសចាញ់ឧបាយកល អាខិលអាខ្វាច ក៏ខឹងនឹងខ្មោចសេដ្ឋីស្លាប់ហើយចេះស្ដីហៅអស្ចារ្យ ឥឡូវនឹងបើកក្ដារឱ្យច្បាស់ ចាស់ៗហាមព្រមថា "មើលមុខខ្មោចមិនបាន ខ្លាចដេកយប់ទៅមមើមមាយ ម្លោះហើយក៏ជឿជាក់យកសំពត់អាវស្លៀកពាក់ និង កន្ទេលពូកខ្នល់ខ្នើយហើយថែមតុថាសចានល្អៗ អំបិលប្រហុក៤ក្រឡ អង្ករ៥ការុងដាក់ផ្លូកទៅឲ្យអាខ្វាចអាខិល បង្ខិលរទេះយ៉ាងធំ ជជែកយំទឹកភ្នែកឱ្យដោយខឹងដោយបញ្ឆោតទាំងស្រីទាំងប្រុស ហើយក៏ដឹកក្របី១នឹមទឹមរទេះប្រគល់ឱ្យអាខ្វាចទៅ" ។ អានោះត្រេកអរឡើងបររទេះចេញទៅ អ្នកទាំងអស់ដែលនៅចេះតែជ្រួលមិនស្រួលចិត្ត ព្រោះដ្បិតខឹងនិងស្ដាយ ។ អាខិលលួចនាយអាយលបចេញប្រិច រត់តាមទៅបន្តិចក៏ទាន់រទេះ ហើយនិយាយគ្នាថា " យើងបានទ្រព្យរបស់ តែទាស់នឹងឃ្លានបាយ បើឈប់ដណ្ដាំបាយនៅរៀងអាយក្រែងមិនស្ទាត់ ខ្លាចចោរតាមមកប្លន់យកទ្រព្យមួយរទេះ បើដូច្នោះ ឯងឈប់ចាំអញៗ ទៅសុំបាយគេខ្លះយកមកឱ្យឯង" ។ អាមួយព្រមហើយអាមួយក៏ដើរទៅរកថ្នាំតាមផ្លូវ យកមកលាយបាយឲ្យពុលស្លាប់អន្តរាយ នឹងយកទ្រព្យរបស់នោះតែម្នាក់ឯង ។ ឯអាមួយនៅចាំរទេះក៏ធ្វើខ្នារដាក់ស្នាក់ផ្លូវបម្រុងឲ្យត្រូវអានោះស្លាប់ នឹងយកទ្រព្យតែម្នាក់ឯងដែរ ។ វេលានោះអាមួយទៅសុំបាយគេស៊ីៗ រួចហើយសុំមួយចានផ្ញើសំឡាញ់ គេមិនកំណាញ់ក៏រកស្លឹកចេកខ្ចប់ឱ្យមានទាំងត្រីអាំងផង ។ អានោះក៏លាគេដើរចេញមក ហើយយកថ្នាំប្រឡាក់បាយ មកដល់ខាងអាយក៏ត្រូវនឹងខ្នារនោះស្លាប់ អាមួយដើរប្រញាប់ចាប់បាយស៊ីទើបនឹងស្កាំ អាឆេះពិសថ្នាំក៏ពុលស្លាប់បន្ទាប់គ្នា ។ ឯក្របីនោះក៏អូសរទេះចូលក្នុងព្រៃរតេករតោក ទៅជ្រកក្នុងទឹកត្រពាំង ប្រឆាំងដាច់ខ្សែទាមដេកត្រាំទឹកទៅ ។ ដល់វេលាព្រឹកមានបុរស

ម្នាក់ ដើរទៅឃើញទ្រព្យរបស់ទាំងអស់នៅក្នុងព្រៃនឹកម្តងភ័យនឹកម្តងអរថាឯងអ្នកក្រមិនដែលប្រទះទ្រព្យច្រើនណាស់ដូច្នេះ បើលៃលកយកទៅរបស់ខ្លួន ក្រែងពុំបានសុខក៏រុញរទេះសំរុកទៅទុកក្នុងព្រៃ ចងក្របីដាប់ត្រឡប់ទៅផ្ទះវិញ ហើយក៏ពិសោធន៍មាយាទប្រពន្ធ ដោយគិតថា "បើប្រពន្ធមាយាទល្អ នឹងយកទ្រព្យនោះទុកជារបស់ខ្លួនបើនិយាយអ៊ីទៅមិនចេះលាក់នឹងយករបស់ទាំងនោះទៅជូនរាជការផែនដី ប្រយោជន៍ដើម្បីឱ្យសុខខ្លួន" ។ គិតហើយទៅដល់ផ្ទះក៏កុហកប្រាប់ប្រពន្ធថា "អញជុះអាចម៍មិញៗមានសត្វក្អែកមួយ ហើរចេញពីក្តិត តែឯងអាណិតបិទមាត់ឱ្យឈឹង កុំឱ្យនរណាគេដឹងមួយជាពីរ តែចូលត្រចៀកគេវាបែកការណ៍អាក្រក់ណាស់ កើតមានជំនុំជម្រះសួរទៅសួរមក ហើយគ្មានទាំងសាក្សីបានដឹងនឹងអាងក្រែងគេយកអញទៅឆ្កាង ឬ យកទៅដាក់គុក" ។ ប្រពន្ធមិនលាក់ទុកក៏ដើរប្រាប់គេថា "មានក្អែកពីរ ហើរចេញពីក្តិតប្តីអញតែឯងកុំមាត់" មេមួយទៀតមិនអត់ទៅប្រាប់គេថែមថា ក្អែក៥ប្រាប់លើសៗគ្នាដរាបដល់ក្អែក១០ ។ រឿងនោះក៏ជ្រួតជ្រាបទៅដល់ព្រះមហាក្សត្រៗ ទ្រង់ចាត់ប្រើអាមាត្យឲ្យស្រាវជ្រាវរកដល់បុរសនោះៗក៏ថ្វាយបង្គំគាល់ស្តេចទ្រង់ឆ្ងល់ត្រាស់សួរថា "មែន ឬ មិនមែន" ។ បុរសក្រាបទូលថា "ទូលព្រះបង្គំជាខ្ញុំកុហកប្រពន្ធចង់ដឹងចិត្តព្រោះតឿតឃើញទ្រព្យច្រើន" ។ បុរសនោះក្រាបទូលដូចខាងលើ ហើយក្រាបបង្គំលាទៅទឹមរទេះយកមកថ្វាយស្តេចៗ ស្តេចទ្រង់ព្រះរាជទានឲ្យបុរសនោះពាក់កណ្តាលៗដាក់ឃ្លាំង ។

## ធ្វើផ្ទះកុំដាក់ជណ្តើរ លោះខ្ញុំប្រើកុំឱ្យបាយស៊ី